# យោបល់ និងអនុសាសន៍នានា៖

# ប្រកាសអន្តរក្រសួងស្តីពីការហាមឃាត់ការប្រើប្រាស់ពលកម្មជនជាប់ឃុំក្នុងពន្ធនាគារ ដើម្បីផលិតទំនិញនាំចេញ

របាយការណ៍សង្ខេប លីកាដូ

ខែឧសភា ឆ្នាំ២០១២


សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

LICADHO

Cambodian League for the Promotion and Defense of Human Rights



*This project is funded by the European Union*

*"The contents of this publication are the sole responsibility of LICADHO and can in no way be taken to reflect the views of the European Union."*

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងឃ្លាំមើលរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង១២ ខេត្ត-រាជធានីផ្សេងទៀត។

អង្គការលីកាដូ អនុវត្តសកម្មភាពរបស់ខ្លួនតាមរយៈកម្មវិធីធំៗពីរៈ

**កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្សៈ**

- **ឃ្លាំមើលការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋលើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារៈ** បុគ្គលិកធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន។
- **ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់ៈ** ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗ ទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។
- **ការឃ្លាំមើលពន្ធនាគារៈ** អ្នកស្រាវជ្រាវពន្ធនាគារធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានា ថាជនជាប់ឃុំទទួលបាននូវតំណាងផ្នែកច្បាប់។
- **ជំនួយផ្នែកវេជ្ជសាស្ត្រៈ** ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារចំនួន១២ កន្លែង។ បន្ថែមពីលើនេះ ក៏ជួយផ្តល់សេវាវេជ្ជសាស្ត្រ និងបញ្ជូនជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សទៅកាន់មន្ទីរពេទ្យ។

- **សេវាកម្មសង្គមកិច្ចៈ** ក្រុមការងារធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយសម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**កម្មវិធីទំនាក់ទំនង និងការទាក់ទាញមតិគាំទ្រៈ**

- **ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិៈ** អ្នកហ្វឹកហ្វឺន និងអ្នកតស៊ូមតិធ្វើការអប់រំដល់សាធារណជនអំពីសិទ្ធិស្ត្រី និងសិទ្ធិកុមារបង្កើតបណ្តាញការពារនៅតាមមូលដ្ឋាន និងធ្វើការតស៊ូមតិដើម្បីឲ្យមានការផ្លាស់ប្តូរសង្គម និងគោរពច្បាប់។
- **ការតស៊ូមតិជាសាធារណៈ និងតាមសហគមន៍ៈ** ករណីរំលោភសិទ្ធិមនុស្សដែលស៊ើបអង្កេតដោយលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិតជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍)។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទងៈ**


លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ

អាសយដ្ឋានៈ អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)

ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទៈ (+៨៥៥) ២៣ ៧២៧ ១០២/២១៦ ៦០២ ទូរសារៈ (+៨៥៥) ២៣ ៧២៧ ១០២/ ២១៧ ៦២៦

អ៊ីម៉ែលៈ contact@licadho-cambodia.org

គេហទំព័រៈ http://www.licadho-cambodia.org

# មាតិកា

**សេចក្តីសង្ខេប**........................................................................................................១

**ការវិភាគ: បញ្ហាចម្បងៗជុំវិញប្រកាសស្តីពីពលកម្មជនជាប់ឃុំក្នុងពន្ធនាគារ ៤**

បញ្ហាដែលទាក់ទងនឹងប្រកាសនេះ................................................................ ៤

បទបញ្ញត្តិមានលក្ខណៈមិនច្បាស់លាស់ និងការប្រតិបត្តិគ្មានភាពប្រាកដប្រជា.៧

មជ្ឈដ្ឋានអន្តរជាតិ: ការនាំចេញមិនមែនជាបញ្ហាតែមួយមុខប៉ុណ្ណោះទេ..........១១

*អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ២៩*............................................១១

*លក្ខខណ្ឌទាំងឡាយ ដែលប្រហាក់ប្រហែលនឹងទំនាក់ទំនងការងារសេរី*.....១២

*ស្ថានភាពក្នុងពន្ធនាគារនៅកម្ពុជា*........................................................... ១៤

*ជនជាប់ឃុំជាចរន្តប្រាក់ចំណូល*.................................................................. ១៦

□□□

# សេចក្តីសង្ខេប

នៅខែធ្នូ ឆ្នាំ២០១១ ប្រទេសកម្ពុជាបានអនុម័តច្បាប់ថ្មីស្តីពីពន្ធនាគារ ដែលបច្ចុប្បន្នដើរតួនាទីជាអាជ្ញាធរផ្លូវច្បាប់បឋមរបស់ព្រះរាជាណាចក្រកម្ពុជា សម្រាប់គ្រប់គ្រងប្រព័ន្ធ[១] ពន្ធនាគារ។

មុនពេលអនុម័តច្បាប់នេះអង្គការលីកាដូ បានលើកឡើងនូវកង្វល់យ៉ាងធ្ងន់ធ្ងរអំពីមាត្រា៧១ ជាបទបញ្ញត្តិមួយក្នុងច្បាប់ ដែលអនុញ្ញាតឲ្យក្រុមហ៊ុនឯកជនប្រើប្រាស់ជនជាប់ឃុំជានិយោជិត។[២] ការចាត់ចែងបែបនេះ ជាញឹកញាប់ត្រូវហាមឃាត់ដោយច្បាប់អន្តរជាតិ ហើយទម្លាប់អនុវត្តនេះ ក៏ត្រូវហាមឃាត់យ៉ាងជាក់ច្បាស់តាមបទបញ្ជា[៣]ពន្ធនាគារមុនៗ។

បន្ថែមទៅលើកង្វល់នេះ បណ្តាញសារព័ត៌មានភាគច្រើនបានផ្សព្វផ្សាយរបាយការណ៍ទាំងឡាយដែលលើកឡើងថា ក្រុមហ៊ុនកម្ពុជាបានប្រើប្រាស់ជនជាប់ឃុំដើម្បីផលិតសំលៀកបំពាក់សម្រាប់នាំចេញ។[៤] សូម្បីតែទម្លាប់អនុវត្តនេះ ក៏ត្រូវបានលើកឡើង និងថ្កោលទោស ដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម[៥] ដោយសារតែអ្នកទិញសំលៀកបំពាក់ថ្នាក់អន្តរជាតិស្ទើរតែទាំងអស់ ហាមប្រាមអ្នកម៉ៅការ[៦]របស់ពួកគេមិនឲ្យប្រើប្រាស់ពលកម្ម

---

[១] អគ្គនាយកដ្ឋានពន្ធនាគារបច្ចុប្បន្នមានសមត្ថកិច្ចទៅលើពន្ធនាគារចំនួន ២៧ ក្នុងប្រទេសកម្ពុជា រាប់ទាំងពន្ធនាគារ ដែលទើបបើកថ្មីនៅខេត្តឧត្តមានជ័យ។ អង្គការលីកាដូ ឃ្លាំមើលពន្ធនាគារចំនួន ១៨ ក្នុងចំណោមពន្ធនាគារទាំងនេះ រាប់ទាំងពន្ធនាគារយោធាផងនៅទួលស្លែង ដែលមិនមែនស្ថិតនៅក្រោមសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានពន្ធនាគារឡើយ។

[២] សូមមើល "យោបល់ និងបណ្តាអនុសាសន៍ផ្លូវច្បាប់ស្តីពីសេចក្តីព្រាងច្បាប់ពន្ធនាគារ" របាយការណ៍អង្គការលីកាដូ ចេញផ្សាយនៅខែតុលា ឆ្នាំ២០១១ (មាននៅក្នុងគេហទំព័រ: http://www.licadho-cambodia.org/reports.php?perm=161)។

[៣] នីតិវិធីពន្ធនាគារលេខ ១១ កថាខ័ណ្ឌ៣.៤ (២០០៣) បទបញ្ជាទាំងឡាយនេះ មិនត្រូវបានលុបចោលតាមបច្ចេកទេសទេ ប៉ុន្តែតាមការអនុវត្តន៍ជាក់ស្តែង នីតិវិធីពន្ធនាគារលេខ ១១ ត្រូវបានជំនួសដោយច្បាប់ពន្ធនាគារ។

[៤] សូមមើល ឧទាហរណ៍ Sebastian Strangio " ប្រទេសកម្ពុជា: កង្វល់ពលកម្មជនជាប់ឃុំនៅតាមពន្ធនាគារ" សារព័ត៌មាន The Global Post នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១១ (មាននៅក្នុងគេហទំព័រ: http://www.globalpost.com/dispatch/news/regions/asia-pacific/111206/ cambodia-prison-labor-garments-exports-ILO)។ Abby Seiff and Kuch Naren "កម្មវិធីផលិតស្បែកជើងនៅក្នុងពន្ធនាគារប្រកាសបើកឲ្យប្រើដោយសម្ងាត់" កាសែត The Cambodia Daily នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១។ Liam Cochrane "អះអាងថា ការសន្យាខាងពលកម្មជនជាប់ឃុំនៅតាមពន្ធនាគារកម្ពុជាត្រូវបានរំលោភបំពាន" វិទ្យុអូស្ត្រាលី នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១១ (មាននៅក្នុងគេហទំព័រ: http://www .radioaustralia.net.au/ international/2011-12-12/claims-cambodian-prison-labour-pledge-broken/282720)។

[៥] Abby Seiff "មន្ត្រីទាំងឡាយផ្តើមរៀបចំឲ្យបានសមស្របតាមខ្នាតបន្ទាត់នូវអ្នកម៉ៅការសំលៀកបំពាក់ ដែលពិបាកគ្រប់គ្រង" កាសែត The Cambodia Daily នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១១។

[៦] ជាឧទាហរណ៍សូមមើល "លក្ខខណ្ឌកិច្ចសន្យាសម្រាប់ដៃគូពាណិជ្ជកម្មរបស់ Kohl" មាននៅក្នុងគេហទំព័រ: http://www.kohlscorporation .com/Suppliers/Forms/Kohl%27s_Terms_of_Engagement%20%28as%20of%2006%2015%2006%29.pdf ។

នៅតាមពន្ធនាគារ ហើយប្រទេសមួយចំនួនក៏បានហាមប្រាមដាច់ខាតមិនឲ្យនាំចូលនូវទំនិញ[៧]បែបនេះផងដែរ។

ដូច្នេះមាត្រា៧១ មិនគ្រាន់តែត្រូវបានបង្កើតឡើង ដោយផ្អែកលើមូលដ្ឋានច្បាប់មិនស្មោះត្រង់ប៉ុណ្ណោះទេ ប៉ុន្តែមាត្រានេះ គំរាមធ្វើឲ្យខូចកិត្យានុភាពវិស័យកាត់ដេរសំលៀកបំពាក់របស់ប្រទេសកម្ពុជាផងដែរ ជាឧស្សាហកម្មវិនិយោគទុន ៤ កោដិដុល្លារអាមេរិកដែលប្រើប្រាស់កម្មករប្រមាណ ៣៣៥,០០០ នាក់ ហើយដែលទទួលបន្ទុកនាំផលិតផលចេញចំនួន ៨៥% ក្នុងចំណោមផលិតផលនាំចេញរបស់ប្រទេសកម្ពុជាទាំងអស់។[៨]

អង្គការលីកាដូ និងអង្គការផ្សេងៗទៀត បានជម្រុញរដ្ឋសភាឲ្យធ្វើវិសោធនកម្មមាត្រា ៧១ ប៉ុន្តែនៅទីបំផុតមាត្រានេះ ត្រូវបានអនុម័តដោយគ្មានការកែប្រែឡើយ។

អស់រយៈពេល ៣ខែ បន្ទាប់ពីបានអនុម័តច្បាប់នេះ រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការមួយចំនួន ដើម្បីឆ្ពោះទៅរកការកែតម្រូវកំហុសឆ្គងនានាក្នុងមាត្រា ៧១ នៃច្បាប់នេះ។ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ រដ្ឋាភិបាលបានចេញ "ប្រកាសអន្តរក្រសួងស្តីពីការហាមឃាត់ការប្រើប្រាស់ពលកម្មជនជាប់ឃុំក្នុងពន្ធនាគារ ដើម្បីផលិតទំនិញនាំចេញ"។

ប្រកាសនេះ - ចេញរួមគ្នាដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រសួងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីក្រសួងការងារ - ហាមឃាត់សហគ្រាសទាំងអស់មិនឲ្យប្រើជនជាប់ឃុំអោយផលិតទំនិញនាំចេញ។ ប្រកាសនេះ ចែងពីការផ្តន្ទាទោសផងដែរទៅលើអង្គភាពទាំងឡាយណាដែលប្រើជនជាប់ឃុំ ហើយកម្មវិធីពលកម្មជនជាប់ឃុំក្នុងពន្ធនាគារតម្រូវឲ្យរដ្ឋជា "អ្នកគ្រប់គ្រង" ដើម្បីឲ្យកម្មវិធីទាំងនេះ បម្រើផលប្រយោជន៍សាធារណៈ។

អង្គការលីកាដូ ជឿជាក់ថា ប្រកាសនេះ គឺជាជំហានមួយក្នុងទិសដៅដ៏ត្រឹមត្រូវ ប៉ុន្តែកង្វល់ជាច្រើននៅតែបន្តមាននៅឡើយ។

ទី១ មានការខកចិត្តដែលថា ចំណុចសំខាន់មួយនៃច្បាប់ គឺមានតែនៅក្នុងប្រកាសមួយជាបទបញ្ញាកំរិតទាប ដែលមិនមានលក្ខណៈខ្លាំងដូចច្បាប់ពិតៗ ហើយមានភាពងាយស្រួលការធ្វើវិសោធនកម្ម។

---

[៧] ជាឧទាហរណ៍សូមមើល ច្បាប់ស្តីពីការកំណត់ពន្ធអាមេរិកនៅឆ្នាំ១៩៣០ ផ្នែក ៣០៧ (ចងក្រងជាក្រមនៅ ១៩ U.S.C. § ១៣០៧)។

[៨] Xinhua "ឧស្សាហកម្មកាត់ដេរសំលៀកបំពាក់របស់ប្រទេសកម្ពុជា បង្កើតការងារបានចំនួន ៣៣៥,៤០០ នៅឆ្នាំ២០១១" នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២ (មាននៅក្នុងគេហទំព័រ: http://www.chinadaily.com.cn/xinhua/2012-03-13/content_5406864.html)។

ទី២ ប្រកាសនេះ មានលក្ខណៈមិនច្បាស់លាស់ក្នុងវិស័យសំខាន់ៗភាគច្រើននាំឲ្យពាក្យពេជ្រគ្មានន័យតាមទស្សនៈច្បាប់។ ហេតុដូច្នេះ មិនមានការធានាសម្រាប់ការប្រតិបត្តិប្រកាសនេះឡើយ។

ឧទាហរណ៍មាត្រា ៥ អនុញ្ញាតឲ្យអាជ្ញាធរដកហូតអាជ្ញាប័ណ្ណនាំចេញរបស់អង្គភាពមួយក្នុងករណី "មិនព្រមរាងចាល" ក្នុងការរំលោភបំពានទៅលើប្រកាសនេះ។ ប៉ុន្តែប្រកាសនេះមិនកំណត់និយមន័យពាក្យ "មិនរាងចាល" ដែលធ្វើឲ្យការប្រតិបត្តិមិនអាចព្យាករណ៍ទុកមុនបាន។ នៅពេលជាមួយគ្នានេះ មាត្រា ២ តម្រូវថា កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងពន្ធនាគារត្រូវតែ "បម្រើផលប្រយោជន៍សាធារណៈ" ការរៀបឃ្លាឃ្លោងទូលំទូលាយនេះអាចនាំឲ្យមានការបកស្រាយមានន័យយ៉ាងច្រើន។

ជាចុងក្រោយថ្វីបើមានការហាមឃាត់ដោយប្រកាសនេះ មិនឲ្យនាំចេញទំនិញដែលផលិតដោយជនជាប់ឃុំក្នុងពន្ធនាគារ ត្រូវបានស្វាគមន៍ក៏ដោយ ប្រកាសនេះដោះស្រាយតែទិដ្ឋភាពនៃបញ្ហាមួយជ្រុងប៉ុណ្ណោះ ដែលចោទឡើងតាមមាត្រា ៧១ នៃច្បាប់ពន្ធនាគារ។ តាមច្បាប់អន្តរជាតិកិច្ចសន្យាស្តីពីពលកម្មជនជាប់ឃុំក្នុងពន្ធនាគារ ដែលជួលទៅឲ្យក្រុមហ៊ុនឯកជន គឺជាស្ថានភាពផ្លូវច្បាប់មួយដ៏គ្រោះថ្នាក់ ទោះបីផលិតផលទាំងនោះលក់តែក្នុងប្រទេសក៏ដោយ។ ត្រូវមានប្រព័ន្ធត្រួតពិនិត្យ និងថ្លឹងថ្លែងអំណាចមួយចំនួន ដែលត្រូវដាក់ឲ្យដំណើរការ។ គិតមកត្រឹមបច្ចុប្បន្ននេះ ប្រព័ន្ធបែបនេះមិនមានចែងនៅក្នុងច្បាប់កម្ពុជាទេ។ នៅចំពោះមុខត្រូវមានច្បាប់បន្ថែមទៀត និងការប្រតិបត្តិឲ្យបានត្រឹម។



*អ្នកជាប់ឃុំជម្រះស្មៅក្នុងបរិវេណមណ្ឌលអប់រំកែប្រែទី៤ ខេត្តពោធិ៍សាត់*

# ការវិភាគ: បញ្ហាចម្បងៗជុំវិញប្រកាសស្ដីពីពលកម្មជនជាប់ឃុំក្នុងពន្ធនាគារ

## បញ្ហាដែលទាក់ទងនឹងប្រកាសនេះ

អង្គការលីកាដូ សូមស្វាគមន៍ប្រកាសអន្តរក្រសួងដែលហាមឃាត់ការប្រើប្រាស់ពលកម្មជនជាប់ឃុំក្នុងពន្ធនាគារ ដើម្បីផលិតទំនិញនាំចេញ។ ប្រកាសនេះ គឺជាជំហានមួយដ៏សំខាន់ឆ្ពោះទៅរកការសំរេចបាននូវគោលដៅ ២ ខុសគ្នា ប៉ុន្តែជាគោលដៅដែលប្រទាក់ក្រឡាគ្នា: ការពារជនជាប់ឃុំពីការកេងប្រវ័ញ្ច និងថែរក្សាកិត្យានុភាពប្រទេសកម្ពុជា ជាផលិតករទទួលខុសត្រូវផ្នែកសង្គម ក្នុងការលក់ផលិតផលវាយនភណ្ឌទៅឲ្យអ្នកទិញបរទេស។



*អ្នកជាប់ឃុំទទួលវគ្គបណ្ដុះបណ្ដាលជំនាញខ្លីៗ ឧបត្ថម្ភដោយអង្គការក្រៅរដ្ឋាភិបាលក្នុងពន្ធនាគារ ខេត្តព្រះសីហនុ*

ប៉ុន្តែ នៅតែមានការខកចិត្តនៅឡើយ ដែលថា គោលដៅសំខាន់ៗបែបនេះ មានតែនៅក្នុងប្រកាសប៉ុណ្ណោះ ហើយមិនមានចែងនៅក្នុងច្បាប់ ដែលមានកំរិតខ្ពស់ជាងនេះឡើយ ពោលដូចជានៅក្នុងច្បាប់ពន្ធនាគារនេះ។

ប្រកាស គឺគ្រាន់តែជាសេចក្ដីសំរេចកំរិតអន្តរក្រសួង ឬ កំរិតក្រសួងដែលត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រី[៩]សាមីក្រសួងពាក់ព័ន្ធ។ នៅក្នុងឋានានុក្រមឯកសារគតិយុត្តិនៅប្រទេសកម្ពុជា ប្រកាសស្ថិតនៅលំដាប់លេខទី៥ បន្ទាប់ពីរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រិត្យ និងអនុក្រិត្យ។[១០] បើប្រៀបធៀបទៅនឹងច្បាប់ទាំងនេះ ប្រកាសមានកំលាំងគតិយុត្តិខ្សោយជាងគេ។

---

[៩] "កម្រងឯកសារច្បាប់មួយចំនួន ដែលកំពុងអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា" ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា មាននៅក្នុងគេហទំព័រ: http://cambodia.ohchr.org/klc_pages/klc_english.htm។

[១០] យោងឯកសារដូចគ្នានឹងជើងទំព័រទី៩។

មិនដូចច្បាប់ដែលត្រូវបានអនុម័តតាមការបោះឆ្នោតពីរដ្ឋសភា និងព្រឹទ្ធសភាទេ ប្រកាសអាចត្រូវកែប្រែភ្លាមៗ ហើយគ្រាន់តែតម្រូវឲ្យមានការចុះហត្ថលេខាពីរដ្ឋមន្ត្រីពាក់ពាន់មួយរូប ឬ ច្រើនរូបតែប៉ុណ្ណោះ។ មិនចាំបាច់ឲ្យមានកិច្ចពិគ្រោះយោបល់ជាសាធារណៈ ឬតាមផ្លូវច្បាប់ឡើយ។ ប្រកាសអាចមានសុពលភាពនៅថ្ងៃនេះ ហើយក៏អាចអស់សុពលភាពទៅវិញនៅថ្ងៃស្អែក ដោយកម្រផ្ដល់ព័ត៌មានឲ្យសាធារណៈជនបានដឹងជាមុនចំពោះការកែប្រែនេះណាស់។

ការប្រើប្រាស់ប្រកាសនៅក្នុងករណីនេះ គឺជាការសង្ស័យផងដែរ ដោយសារប្រវត្តិពលកម្មជនជាប់ឃុំនៅតាមពន្ធនាគារមានបញ្ហានៅប្រទេសកម្ពុជា។ ផ្អែកលើរបាយការណ៍យ៉ាងច្រើនតាមប្រព័ន្ធផ្សាយព័ត៌មាន រដ្ឋាភិបាលទំនងជាបានជួបប្រទះនូវការលំបាកធ្ងន់ធ្ងរក្នុងការបញ្ឈប់ការផលិតសំលៀកបំពាក់កាត់ដេរនៅតាមពន្ធនាគារ បើទុកជារដ្ឋាភិបាលបានសន្យាយ៉ាងដូច្នោះជាសារធារណៈក៏ដោយ។[១១]

សំលៀកបំពាក់កាត់ដេរដែលសង្ស័យថា ជាគោលដៅនាំចេញកំពុងត្រូវបានផលិតនៅក្នុងរោងជាងនៅតាមពន្ធនាគារចាប់តាំងពីដើមឆ្នាំ២០០៩។[១២] ប្រភពរបស់អង្គការលីកាដូ បង្ហាញថា រដ្ឋាភិបាលបានដឹងពីបញ្ហានេះនៅដើមឆ្នាំ២០១០ ហើយផលិតផលដែលសង្ស័យ ថានាំចេញបានបញ្ឈប់នៅចុងឆមាសទី២ ក្នុងឆ្នាំ២០១០។

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១០ ឯកឧត្តម ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបានសរសេរលិខិតមួយច្បាប់ជូនអ្នកទិញសំលៀកបំពាក់កាត់ដេរថ្នាក់អន្តរជាតិ - ទំនងជាលិខិតតបទៅនឹងកង្វល់នានា ដែលអ្នកទិញទាំងនេះបានលើកឡើង - ដោយទទួលស្គាល់ថាសំលៀកបំពាក់កាត់ដេរ ត្រូវបានផលិតឡើងនៅតាមពន្ធនាគារចំនួន ២ គឺមណ្ឌលអប់រំកែប្រែទី ១ និងមណ្ឌលអប់រំកែប្រែទី ២។[១៣] លិខិតនោះសរសេរថា សំលៀកបំពាក់កាត់ដេរត្រូវបាន "លក់ទៅឲ្យរោងចក្រ/អ្នកម៉ៅការដែលមិនមានអាជ្ញាប័ណ្ណ" ហើយថានេះជា "ការយល់ច្រឡំមួយ" ដែលនឹងមិនអាចកើតមានទៀតឡើយ។[១៤]

---

[១១] សូមមើល Sebastian Strangio "ប្រទេសកម្ពុជា: កង្វល់ពលកម្មជនជាប់ឃុំនៅតាមពន្ធនាគារ" សារព័ត៌មាន ," The Global Post, supra ។

[១២] យោងឯកសារដូចគ្នានឹងជើងទំព័រទី១១។

[១៣] Abby Seiff "លិខិតក្រសួងបំភ្លឺយ៉ាងច្បាស់អំពីពលកម្មជនជាប់ឃុំនៅតាមពន្ធនាគារ" កាសែត The Cambodia Daily ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១១។

[១៤] យោងឯកសារដូចគ្នានឹងជើងទំព័រទី១៣។

ប៉ុន្តែប្រភពរបស់អង្គការលីកាដូ បង្ហាញថាការផលិតសំលៀកបំពាក់បានចាប់ផ្តើមឡើងវិញនៅដើមឆ្នាំ២០១១ ហើយនៅតែបន្តផលិតអស់រយៈពេលតែប៉ុន្មានខែប៉ុណ្ណោះ មុនពេលបញ្ឈប់ទៅវិញក្នុងរដូវប្រាំងនៅឆ្នាំ២០១១។ នៅត្រង់ចំណុចនោះ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានសរសេរលិខិតមួយច្បាប់ជូនសមាគមរោងចក្រកាត់ដេរសំលៀកបំពាក់កម្ពុជា (GMAC) ដោយធ្វើការបញ្ជាក់ពីបញ្ហានេះ។ ឯកឧត្តម ចម ប្រសិទ្ធ សរសេរថា[១៥] អ្នកមៅការមិនបានចុះបញ្ជីមួយចំនួន រួមគំនិតជាមួយរោងចក្រមួយចំនួន ដើម្បីប្រើពលកម្មជនជាប់ឃុំដោយអសីលធម៌សម្រាប់ផលិតសំលៀកបំពាក់ ហើយហ៊ានផ្ទេរផលិតផលពាក់កណ្តាលសំរេចទៅឲ្យជនជាប់ឃុំដើម្បីផលិតសំរេចសម្រាប់នាំចេញ។ ឯកឧត្តម ចម ប្រសិទ្ធ សរសេរបន្ថែមទៀតដោយកត់សម្គាល់ថា បញ្ហានេះ "គឺវាបានកើតមាននៅអំឡុងអតីតកាល"។[១៦]

ប៉ុន្តែ ២ខែ ក្រោយមកប្រព័ន្ធផ្សាយព័ត៌មានបានរាយការណ៍ថា ក្រុមហ៊ុន New Star Shoes ជាសមាជិករបស់ GMAC ដែលតាមដឹងមកបាននាំចេញផលិតផលទៅប្រទេសជប៉ុន កាណាដា និងសហរដ្ឋអាមេរិក ទើបតែបានបើករោងជាងមួយនៅពន្ធនាគារ[១៧]ខេត្តព្រះសីហនុ។ ក្រោយមកមិនដល់ ២សប្តាហ៍ផង រោងជាងនោះ ទំនងជាត្រូវបិទវិញ ប្រធានពន្ធនាគារបដិសេធថា មិនដែលធ្លាប់មាន[១៨]រោងជាងទេ។ ដោយឡែកកម្មវិធីផលិតសំលៀកបំពាក់កាត់ដេរមួយនៅពន្ធនាគារខេត្តបាត់ដំបង ទំនងជាបន្តដំណើរការរហូតមកទល់បច្ចុប្បន្ននេះ។[១៩]

ហេតុដូច្នេះ បញ្ហាជាសក្តានុពលជាមួយមាត្រា ៧១ នៃច្បាប់ពន្ធនាគារទំនងជាបានលេចឡើងអស់រយៈពេលជាច្រើនឆ្នាំមុនពេលអនុម័តច្បាប់នេះ ហើយនៅតែមិនទាន់បានធ្វើអ្វីសោះដើម្បីកែប្រែអត្ថបទច្បាប់នេះ។ ច្បាប់នេះ ត្រូវបានអនុម័តតាមខ្លឹមសារដើមទាំងស្រុង។

---

[១៥] Abby Seiff "មន្ត្រីទាំងឡាយផ្តើមរៀបចំឲ្យបានសមស្របតាមខ្នាតបន្ទាត់នូវអ្នកមៅការសំលៀកបំពាក់ ដែលពិបាកគ្រប់គ្រង" កាសែត The Cambodia Daily នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១១។

[១៦] យោងឯកសារដូចគ្នានឹងជើងទំព័រទី១៥។

[១៧] Abby Seiff and Kuch Naren "កម្មវិធីផលិតស្បែកជើងនៅក្នុងពន្ធនាគារ ប្រកាសបើកឲ្យប្រើដោយសម្ងាត់" កាសែត The Cambodia Daily , supra។

[១៨] Abby Seiff and Kuch Naren "ប្រធានពន្ធនាគារបដិសេធ ថាមិនធ្លាប់មានកម្មវិធីផលិតស្បែកជើងនៅក្នុងពន្ធនាគារ" កាសែត The Cambodia Daily ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១១។

[១៩] Abby Seiff and KuchNaren "ប្រធានពន្ធនាគារទទ្មឹងរង់ចាំច្បាប់ស្តីពីកម្មវិធីពលកម្មជនជាប់ឃុំយ៉ាងអន្ទះសារ" កាសែត The Cambodia Daily ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១។

ថ្វីបើប្រកាសនេះ ផ្តើមចេញដំណើរឆ្ពោះទៅរកការសំរេចគោលដៅមួយដ៏មានប្រយោជន៍ក៏ដោយ ព្រឹត្តិការណ៍ជាបន្តបន្ទាប់ដែលនាំឲ្យចេញប្រកាសនេះ បន្សល់ទុកនូវមន្ទិលសង្ស័យពុំរ៉ែយ៉ាងច្រើន។

- **អនុសាសន៍:** អង្គការលីកាដូ សូមលើកជាអនុសាសន៍ថាមាត្រា ៧១ នៃច្បាប់ពន្ធនាគារត្រូវតែធ្វើវិសោធនកម្ម ដើម្បីហាមឃាត់មិនឲ្យប្រើជនជាប់ឃុំផលិត ឬកែឆ្នៃផលិតផលសម្រាប់នាំចេញ។ ជាឧត្តមគតិមាត្រានេះ ត្រូវធ្វើវិសោធនកម្មដើម្បីហាមឃាត់ក្រុមហ៊ុនឯកជនទាំងអស់កុំឲ្យប្រើជនជាប់ឃុំ លើកលែងតែបំពេញតាមលក្ខខណ្ឌតម្រូវនានានៃអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ២៩ ដូចដែលបានរៀបរាប់ពិស្តារខាងក្រោមនេះ។

## បទបញ្ញត្តមានលក្ខណៈមិនច្បាស់លាស់ និងការប្រតិបត្តគ្មានភាពប្រាកដប្រជា

ប្រកាសលាយលក្ខណ៍អក្សរមួយ បានលើកឡើងយ៉ាងល្អក្នុងវិស័យស្មុលមួយ។ មាត្រា ១ និងមាត្រា ៣ ហាមឃាត់មិនឲ្យនាំចេញមុខទំនិញ ដែលផលិតដោយប្រើពលកម្មជនជាប់ឃុំនៅក្នុងពន្ធនាគារ ហើយព្រមទាំងផ្តន្ទាទោសទៅលើក្រុមហ៊ុនណា ដែលរំលោភបំពានទៅលើវិធាននេះ។ អ្នករំលោភបំពានត្រូវផ្តន្ទាទោស ដោយពិន័យជាប្រាក់ចំនួន ៥ ម៉ឺនដុល្លារអាមេរិក និងផ្អាកអាជ្ញាប័ណ្ណ[២០]នាំចេញរយៈពេល ៣ ខែ។

មាត្រា ៤ ពង្រីកការទទួលខុសត្រូវចំពោះក្រុមហ៊ុនទាំងឡាយក្នុងការផ្គត់ផ្គង់ផលិតផលបើទុកជាពួកគេមិនដឹងថាមុខទំនិញរបស់ពួកគេកំពុងត្រូវបាននាំចេញក៏ដោយ។

ដូចដែលអង្គការលីកាដូ បកស្រាយពន្យល់ប្រកាសនេះ បើក្រុមហ៊ុន ក ទិញពីក្រុមហ៊ុន ខ នូវសំលៀកបំពាក់កាត់ដេរ ដែលផលិតដោយប្រើពលកម្មជនជាប់ឃុំក្នុងពន្ធនាគារ ដោយបិទស្លាកកំណត់តម្លៃថ្មី និងនាំចេញទៅលក់នៅបរទេស ក្រុមហ៊ុនទាំងពីរនឹងត្រូវផ្តន្ទាទោសពីបទរំលោភបំពានប្រកាសនេះ។

ក៏ប៉ុន្តែអង្គការលីកាដូ នៅតែមានកង្វល់ខ្លះៗអំពីថាតើការហាមឃាត់ និងការផ្តន្ទាទោសនឹងដំណើរការយ៉ាងដូចម្តេចក្នុងការអនុវត្តន៍ជាក់ស្តែង។ ប្រកាសនេះ មិនបានហាម

---

[២០] មាត្រា ៣ នៃប្រកាសអន្តរក្រសួងស្តីពីការហាមឃាត់ការប្រើប្រាស់ពលកម្មជនជាប់ឃុំក្នុងពន្ធនាគារ ដើម្បីផលិតទំនិញនាំចេញ ដែលបានបកប្រែជាភាសាអង់គ្លេសក្រៅផ្លូវការ ដោយអង្គការពលកម្មអន្តរជាតិ។

ឃាត់សហគ្រាសឯកជនមិនឲ្យប្រើជនជាប់ឃុំផលិតមុខទំនិញសម្រាប់ប្រើប្រាស់ ក្នុងស្រុកឡើយ។ អាស្រ័យហេតុនេះ តើវាយ៉ាងដូចម្ដេចដែរ ប្រសិនបើក្រុមហ៊ុន ក លក់សំលៀកបំពាក់កាត់ដេរ ផលិតក្នុងពន្ធនាគារទៅឲ្យក្រុមហ៊ុន ខ ដែលក្រុមហ៊ុន ខ ធានាថានឹងលក់សំលៀកបំពាក់ទាំងនេះ តែនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ? ប្រសិនបើក្រុមហ៊ុន ខ នាំចេញមុខទំនិញទាំងនេះទៅលក់នៅបរទេស តើក្រុមហ៊ុន ក ជាអ្នករំលោភបំពានប្រកាសនេះ ឬយ៉ាងណា?

យ៉ាងដូចម្ដេចដែរ ប្រសិនបើក្រុមហ៊ុន ក បោកប្រាស់ក្រុមហ៊ុន ខ អំពីសំលៀកបំពាក់កាត់ដេរដែលចេញមកពីប្រភពពន្ធនាគារ ហើយក្រុមហ៊ុន ខ នាំចេញមុខទំនិញទាំងនេះ? តើក្រុមហ៊ុន ខ ជាអ្នកទទួលខុសត្រូវ ឬយ៉ាងណា?

យើងសង្កេតឃើញថា មិនមែនសេណារីយ៉ូទាំងអស់នេះសុទ្ធតែមិនល្អនោះទេ ដោយសារតែមានមន្ត្រីរដ្ឋាភិបាលខ្លះបានស្ដីបន្ទោសជូនៗទៅលើ "អ្នកម៉ៅការគ្មានអាជ្ញាប័ណ្ណ" ចំពោះបញ្ហានានាពីមុនដោយមានការផលិតសំលៀកបំពាក់កាត់ដេរក្នុងពន្ធនាគារ។ ភាពជាប់ពាក់ព័ន្ធ គឺថាអ្នកម៉ៅការគ្មានអាជ្ញាប័ណ្ណកំពុងធ្វើការងារមិនទៀងទាត់[២១]សម្រាប់ដៃគូដែលមានអាជ្ញាប័ណ្ណ។

អង្គការលីកាដូ ជឿជាក់ថាប្រកាសនេះ គួរត្រូវពន្យល់បកស្រាយដើម្បីផ្ដន្ទាទោសក្រុមហ៊ុន ដោយមិនគិតថាក្រុមហ៊ុននោះបានដឹង ឬមិនបានដឹងពិតប្រាកដថាមុខទំនិញចេញពីប្រភពពន្ធនាគារនោះឡើយ។ ហេតុដូច្នេះ ក្នុងឧទាហរណ៍ខាងលើក្រុមហ៊ុនទាំងពីរជាអ្នកទទួលខុសត្រូវ។ ទោះបីយ៉ាងណាក៏ដោយ គេនៅតែរង់ចាំមើល ថាតើប្រកាសនេះនឹងត្រូវអនុវត្តជាក់ស្ដែងតាមរបៀបនេះ ឬយ៉ាងណា។

- **អនុសាសន៍:** ដើម្បីធ្វើឲ្យប្រាកដប្រជាថា នឹងមិនមានការឆ្លៀតឱកាសសម្រាប់នាំចេញទំនិញពីពន្ធនាគារ អង្គការលីកាដូ សូមលើកអនុសាសន៍ថា ត្រូវតែអនុវត្តឲ្យបានត្រឹមត្រូវបំផុតនូវមាត្រា ១ មាត្រា ៣ និងមាត្រា ៤ នៃប្រកាសនេះ តាមដែលអាចធ្វើទៅបាន។ ជាពិសេសអាជ្ញាធរត្រូវប្រកាន់យកវិធីសាស្ត្រទទួលខុសត្រូវតឹងរ៉ឹងមួយក្នុងការអនុវត្តន៍ ការហាមឃាត់ក្នុងការនាំចេញ។ បទបញ្ញត្តិទាក់ទងនឹង

[២១] ឧទាហរណ៍សូមមើល Abby Seiff "មន្ត្រីទាំងឡាយផ្ដើមរៀបចំឲ្យបានសមស្របតាមខ្នាតបន្ទាត់នូវអ្នកម៉ៅការសំលៀកបំពាក់ដែលពិបាកគ្រប់គ្រង" កាសែត The Cambodia Daily , *supra*; Abby Seiff, "លិខិតក្រសួងបំភ្លឺយ៉ាងច្បាស់អំពីពលកម្មជនជាប់ឃុំនៅតាមពន្ធនាគារ" កាសែត The Cambodia Daily, *supra*.

ការផ្តន្ទាទោស និងការហាមឃាត់ ត្រូវដាក់ឲ្យអនុវត្តចំពោះក្រុមហ៊ុនណាមួយ ដែលនាំចេញមុខទំនិញផលិតក្នុងពន្ធនាគារ ទោះបីអាជ្ញាធរអាចបង្ហាញថា ក្រុមហ៊ុននោះ "បានដឹងពិតប្រាកដ" ឬមិនបានដឹងពីប្រភពទំនិញក៏ដោយ។ ការប្រតិបត្តិមិនបានតឹងរ៉ឹងជាសក្តានុពលនឹងផ្តល់រនាំងបិទបាំងការប្រើប្រាស់ពលកម្មជនជាប់ឃុំក្នុងពន្ធនាគារដើម្បីផលិតទំនិញនាំចេញ។

អាជ្ញាធរគួរពិចារណាអនុម័តការហាមឃាត់ ទៅលើការផលិតសំលៀកបំពាក់កាត់ដេរក្នុងពន្ធនាគារផងដែរ ក្នុងគោលបំណងលុបបំបាត់លទ្ធភាពណាមួយ ដែលនឹងអាចនាំចេញទំនិញបែបនេះ។

មាត្រា ២ នៃប្រកាសនេះ មានបញ្ហាផងដែរ ហើយជាសក្តានុពលមិនត្រឹមត្រូវទេក្នុងប្រកាសនេះ។ មាត្រានេះចែងថា "អនុញ្ញាតឲ្យមានការប្រើប្រាស់ពលកម្មជនជាប់ឃុំក្នុងពន្ធនាគារ ដើម្បីផលិតនូវផលិតផលក្រោមកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងពន្ធនាគារដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋសំដៅបំរើផលប្រយោជន៍សាធារណៈតែប៉ុណ្ណោះ"។[២២]

ថ្វីត្បិតតែបទបញ្ញត្តិនេះ ទំនងជាមានភាពវិជ្ជមាន ក៏ប៉ុន្តែអត្ថន័យពិតប្រាកដរបស់វាមានការលំបាកបកស្រាយ បន្ទាប់ពីបានធ្វើការពិនិត្យយ៉ាងយកចិត្តទុកដាក់។ ជាក់ស្តែងមានសំណួរមួយបានលើកឡើង ថាតើ "ផលប្រយោជន៍សាធារណៈ" មានន័យយ៉ាងដូចម្តេច? តើជនជាប់ឃុំនឹងត្រូវទទួលបានការអនុញ្ញាតឲ្យធ្វើពលកម្ម ដែលជាប្រភេទការងារសាធារណៈតែប៉ុណ្ណោះ ដូចជាការងារផ្លូវថ្នល់ ការផលិតទំនិញសម្រាប់អង្គភាពសាធារណៈ និងការងារផ្សេងៗទៀត ឬយ៉ាងណា? ឬថាតើជនជាប់ឃុំអាចធ្វើការងារឲ្យក្រុមហ៊ុនឯកជន ដែលលក់ទំនិញទៅឲ្យអង្គភាពសាធារណៈ ឬយ៉ាងណា? ឬថាតើពួកគេនឹងត្រូវទទួលការអនុញ្ញាតឲ្យធ្វើការសម្រាប់ក្រុមហ៊ុនឯកជន ដែលលក់ទំនិញលើទីផ្សារចំហក្នុងស្រុក ឬយ៉ាងណា?

ប្រសិនបើមាត្រា ២ ត្រូវបានបកស្រាយក្នុងន័យថា ជនជាប់ឃុំអាចធ្វើការងារសាធារណៈសម្រាប់តែអង្គភាពសាធារណៈប៉ុណ្ណោះនោះ តាមទឡ្ហីករណ៍នេះវាផ្ទុយទៅនឹងមាត្រា ៧១ នៃច្បាប់ពន្ធនាគារ។ មាត្រា ៧១ អនុញ្ញាតឲ្យពន្ធនាគារ "ចុះកិច្ចសន្យាជាមួយរូបវន្តបុគ្គល ឬនីតិបុគ្គល ឬអង្គការជាតិ ឬអង្គការអន្តរជាតិ ដើម្បីបង្កើតការងារសម្រាប់ឧស្សាហកម្ម ពន្ធនាគារ សិប្បកម្ម និងកម្មវិធីកសិកម្ម"។ មាត្រា ៧១ នេះក៏តម្រូវឲ្យប្រព័ន្ធ

---

[២២] មាត្រា ២ នៃច្បាប់ពន្ធនាគារ។

ពន្ធនាគារ "ចុះកិច្ចសន្យាលក់ផលិតផល ដែលបានមកពីឧស្សាហកម្មពន្ធនាគារ សិប្បកម្ម និងកសិកម្មផងដែរ"។

ប្រកាសមិនមានកំលាំងគតិយុត្តិដើម្បីជំនួសច្បាប់ ដែលត្រូវបានអនុម័តយ៉ាងត្រឹមត្រូវឡើយ។ ហេតុដូច្នេះ "ផលប្រយោជន៍សាធារណៈ" មិនអាចត្រូវបានបកស្រាយក្នុងន័យការងារសាធារណៈប៉ុណ្ណោះទេ។

តាមជម្រើសផ្សេង "ផលប្រយោជន៍សាធារណៈ" អាចត្រូវបានបកស្រាយគ្រោបយកពលកម្មជនជាប់ឃុំក្នុងពន្ធនាគារណាមួយ។ ម៉្យាងវិញទៀតការងារណាមួយដែលធ្វើដោយជនជាប់ឃុំអាចត្រូវបានគេកំណត់យ៉ាងទូលំទូលាយជាផលប្រយោជន៍សាធារណៈ ប្រសិនបើការងារនោះ រួមចំណែកក្នុងការស្តារនីតិសម្បទា។ ពាក្យពេជ្រក្នុងមាត្រា ២ ត្រូវការកំណត់ឲ្យបានច្បាស់លាស់បន្ថែមទៀត ដើម្បីឲ្យមាត្រានេះមានន័យទៅបាន។

- **អនុសាសន៍:** គោលដៅជាក់ស្តែងនៃមាត្រា ២ ដែលតម្រូវថា កម្មវិធីពលកម្មជនជាប់ឃុំក្នុងពន្ធនាគារត្រូវដំណើរការក្នុង "ផលប្រយោជន៍សារធារណៈ" ទំនងជាស្ថិតនៅក្រៅវិសាលភាពនៃប្រកាសទាក់ទងនឹងការនាំចេញទំនិញផលិត ដោយពន្ធនាគារ។ បទបញ្ញត្តិនេះ ត្រូវបានគេមើលឃើញមិនត្រឹមត្រូវ ដោយសារវាខ្វះសេចក្តីពិស្តារ។ អង្គការលីកាដូ សូមលើកអនុសាសន៍ដូចតទៅ សូមរដ្ឋាភិបាលមេត្តាអនុម័តអនុក្រិត្យមួយ ឬ ធ្វើវិសោធនកម្មច្បាប់ពន្ធនាគារ ដើម្បីកំណត់ព្រំដែនឲ្យបានជាក់ច្បាស់ក្នុងការគ្រប់គ្រងកម្មវិធីពលកម្មជនជាប់ឃុំក្នុងពន្ធនាគាររបស់ប្រទេសកម្ពុជា។ អង្គការលីកាដូ ជឿជាក់ថា ច្បាប់ក្រោយៗត្រូវហាមឃាត់ការប្រើប្រាស់ពលកម្មជនជាប់ឃុំក្នុងពន្ធនាគារ ដោយអង្គភាពឯកជន ដោយសារបច្ចុប្បន្នលក្ខខណ្ឌទាំងឡាយនៅក្នុងពន្ធនាគារកម្ពុជា មិនមានអំណោយផលគ្រប់គ្រាន់សម្រាប់ឲ្យកម្មវិធីបែបនេះ ដំណើរការបានសមស្របនៅឡើយ។

តាមជម្រើសផ្សេងទៀត ប្រសិនបើរដ្ឋាភិបាលជម្រុញផែនការរបស់ខ្លួន ឲ្យមានដំណើរការទៅមុខដើម្បីជួលជនជាប់ឃុំទៅឲ្យក្រុមហ៊ុនឯកជន នោះច្បាប់ក្រោយៗត្រូវដាក់បញ្ចូលបទដ្ឋានអន្តរជាតិនានា ស្តីពីការរៀបចំចាត់ចែងបែបនេះ។ គោលការណ៍គតិយុត្តិអន្តរជាតិស្តីពីការគ្រប់គ្រងការងារជនជាប់ឃុំ ដោយក្រុមហ៊ុនឯកជនត្រូវបានលើកឡើងយ៉ាងពិស្តារដូចបានពន្យល់បន្ថែមខាងក្រោម។

នៅទីបំផុតមាត្រា ៥ អនុញ្ញាតឲ្យអាជ្ញាធរដកហូតអាជ្ញាប័ណ្ណនាំចេញពីអង្គភាពណាមួយក្នុងករណី "មិនព្រមរាងចាល" ក្នុងការរំលោភបំពានទៅលើប្រកាសនេះ។ ប៉ុន្តែមាត្រានេះមិនបានកំណត់និយមន័យនៃពាក្យ "មិនព្រមរាងចាល" ដែលធ្វើឲ្យការអនុវត្តន៍មិនអាចព្យាករណ៍ទុកជាមុនបាន និងគ្មានសមភាព។

- **អនុសាសន៍:** មាត្រា ៥ នៃប្រកាសនេះ គួរកំណត់ឲ្យបានជាក់ច្បាស់នូវដើមចមសម្រាប់ដកហូតអាជ្ញាប័ណ្ណនាំចេញពីក្រុមហ៊ុនណាមួយ។ ការដកហូតនេះ គួរតែធ្វើឡើងបន្ទាប់ពីមានការរំលោភបំពានលើកទីពីរ។

## មជ្ឈដ្ឋានអន្តរជាតិ: ការនាំចេញមិនមែនជាបញ្ហាតែមួយមុខប៉ុណ្ណោះទេ

កង្វល់ចុងក្រោយរបស់អង្គការលីកាដូ ទាក់ទងនឹងប្រកាសនេះ គឺដែនកំណត់នូវវិសាលភាពរបស់ប្រកាស។ មាត្រា ៧១ នៃច្បាប់ពន្ធនាគារអនុអញ្ញាតឲ្យអង្គភាពឯកជនប្រើប្រាស់ពលកម្មជនជាប់ឃុំក្នុងពន្ធនាគារ ជាផែនការមួយដែលយ៉ាងតិចណាស់បង្កើតនូវបញ្ហាពីរខុសពីគ្នា។ ប្រកាសនេះ លើកយកបញ្ហាតែមួយប៉ុណ្ណោះក្នុងចំណោមបញ្ហាទាំងពីរមកពិភាក្សា គឺលទ្ធភាពដែលទំនិញផលិតដោយពន្ធនាគារនឹងត្រូវបានគេធ្វើការនាំចេញ។ បញ្ហាទីពីរនៅតែជាបញ្ហាដដែល: ស្ថានភាពផ្លូវច្បាប់ប្រកបដោយគ្រោះថ្នាក់ ដែលកើតឡើងនៅពេលសហគ្រាសឯកជនប្រើប្រាស់ពលកម្មជនជាប់ឃុំក្នុងពន្ធនាគារ ទោះជាទំនិញទាំងនោះត្រូវបានផលិតក្នុងពន្ធនាគារសម្រាប់ប្រើប្រាស់ក្នុងស្រុកក៏ដោយ។

## អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ២៩

លិខិតុបករណ៍គតិយុត្តិសំខាន់ស្តីពីពលកម្មជនជាប់ឃុំក្នុងពន្ធនាគារ គឺជាអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ២៩(ILO)ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ននៅឆ្នាំ១៩៦៩[២៣] អនុសញ្ញានេះ ត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់កម្ពុជាតាមរយៈមាត្រា ១៥ នៃច្បាប់ស្តីពីការងាររបស់ប្រទេសកម្ពុជា[២៤] និងតាមរយៈរដ្ឋធម្មនុញ្ញ។[២៥]

---

[២៣] សូមមើលអង្គការពលកម្មអន្តរជាតិ ឯកសារមាននៅក្នុង ILOLEX សំរាប់ប្រទេសកម្ពុជាមាននៅក្នុងគេហទំព័រ: http://www. ilo.org /ilolex/cgi-lex/countrylist.pl?country=Cambodia។

[២៤] មាត្រា១៥ នៃច្បាប់ស្តីពីការងារចែងថា "ការងារដោយបង្ខំ ឬ ជាកាតព្វកិច្ចត្រូវហាមឃាត់ជាដាច់ខាត ដោយអនុលោមតាមអនុសញ្ញាអន្តរជាតិលេខ២៩ ស្តីពីការងារដោយបង្ខំ ឬ ជាកាតព្វកិច្ច"។

[២៥] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។

អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ២៩ ហាមឃាត់បណ្តាប្រទេសហត្ថលេខីមិនឲ្យប្រើពលកម្មដោយបង្ខំ ប៉ុន្តែអនុសញ្ញានេះ ធ្វើការលើកលែងជាក់លាក់សម្រាប់ពលកម្មជនជាប់ឃុំដ៏រាបណាពលកម្មនោះ ត្រូវបានធ្វើដោយទណ្ឌិត ហើយ"ត្រូវអនុវត្តក្រោមការត្រួតពិនិត្យ និងត្រួតត្រាមើលពីអាជ្ញាធរសាធារណៈ ហើយទណ្ឌិតមិនត្រូវបានជួលទៅឲ្យ ឬ ដាក់ឲ្យស្ថិតក្រោមការចាត់ចែងរបស់បុគ្គលឯកជន ក្រុមហ៊ុន ឬសមាគមន៍ឡើយ"។[២៦] ម៉្យាងទៀត អនុសញ្ញានេះ អនុញ្ញាតឲ្យធ្វើពលកម្មដោយបង្ខំក្នុងពន្ធនាគារបាន ដ៏រាបណាពលកម្មនោះត្រូវបានត្រួតពិនិត្យមើលពីអាជ្ញាធរសាធារៈ ហើយជនជាប់ឃុំមិនត្រូវបាន "ជួលទៅ" ឲ្យក្រុមហ៊ុនឯកជនឡើយ។[២៧]

ហេតុដូច្នេះអនុសញ្ញានេះ មិនបានហាមឃាត់ជនជាប់ឃុំមិនឲ្យស្ម័គ្រចិត្តធ្វើការឲ្យសហគ្រាសឯកជនទេ។ ប៉ុន្តែតាមប្រវត្តិរឿងរ៉ាវការដាក់ឲ្យជាប់ពន្ធនាគារមានភាពពាក់ព័ន្ធទៅនឹងការងារជាកាតព្វកិច្ច ហើយជាទូទៅគេសន្មត ថាជនជាប់ឃុំធ្វើការងារដោយបង្ខំ។ ដូចអង្គការពលកម្មអន្តរជាតិបានកត់សម្គាល់ខាងក្រោម:

> លើកលែងតែក្នុងករណីមួយចំនួន ដែលកម្រប៉ុណ្ណោះ ជនជាប់ឃុំធ្វើការងារដោយបង្ខំ។ គាត់មិនអាចជ្រើសរើសយកការងារតាមចិត្ត ដូចកម្មករសេរីឡើយ ប៉ុន្តែជាធម្មតាត្រូវតែធ្វើការងារដែលគេចាត់ឲ្យខ្លួនធ្វើទោះជាការងារអ្វីក៏ដោយ។ ត្រូវបំពេញការងារក្រោមលក្ខខណ្ឌនានា ដែលកំណត់ ដោយសេចក្តីសំរេចជាឯកតោភាគីពីរដ្ឋ ជនជាប់ឃុំគ្មានសំលេងក្នុងបញ្ហានេះទេ ហើយជាធម្មតាមិនអាចប្តឹងតវ៉ាទៅតុលាការបានឡើយ ប្រសិនបើខ្លួនក្លាយជាជនរងគ្រោះពីអំពើអយុត្តិធម៌។[២៨]

## លក្ខខណ្ឌទាំងឡាយ ដែលប្រហាក់ប្រហែលនឹងទំនាក់ទំនងការងារសេរី

ដោយសារតែចរិតលក្ខណៈបង្ខិតបង្ខំប្លែកទៅលើជីវិតជាប់ឃុំក្នុងពន្ធនាគារ គណៈកម្មាធិការអ្នកជំនាញ ILO ដែលជាស្ថាប័នទទួលបន្ទុកការងារបកស្រាយអនុសញ្ញា ILO បាន

[២៦] អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ២៩ ត្រង់មាត្រា២ (២) (គ)។

[២៧] អង្គការពលកម្មអន្តរជាតិ របាយការណ៍ទូទៅនៃគណៈកម្មាធិការអ្នកជំនាញ ស្តីពីការអនុវត្តន៍អនុសញ្ញា និងអនុសាសន៍ទាំងឡាយឆ្នាំ២០១១ កថាខណ្ឌ៨៦ និង១១៩។ គណៈកម្មាធិការអ្នកជំនាញ ILO មានការឈឺចាប់ដោយកត់សម្គាល់ឃើញថា អនុសញ្ញានេះ មានលក្ខខណ្ឌតម្រូវ ២ យ៉ាងដាច់ពីគ្នា - "ការត្រួតពិនិត្យមើលជាសាធារណៈ" និងការហាមឃាត់មិនឲ្យដាក់ជនជាប់ឃុំនៅក្រោមការចាត់ចែងរបស់អង្គភាពឯកជនៈ "ហេតុការណ៍ ដែលថាជនជាប់ឃុំបន្តស្ថិតនៅក្រោមការត្រួតពិនិត្យ និងការត្រួតត្រាមើលពីអាជ្ញាធរសាធារណៈគ្រប់ពេលវេលាមិនមែនមិនឲ្យរដ្ឋាភិបាលបំពេញលក្ខខណ្ឌទីពីរឡើយ ពោលគឺថាទណ្ឌិត/ជនជាប់ឃុំមិនត្រូវបានជួលទៅឲ្យ ឬ ដាក់ឲ្យស្ថិតក្រោមការចាត់ចែងរបស់បុគ្គលឯកជន ក្រុមហ៊ុន ឬ សមាគមឡើយ"។

[២៨] អនុស្សរណៈ ILO ស្តីពីពលកម្មជនជាប់ឃុំក្នុងពន្ធនាគារ ការពិនិត្យឡើងវិញនូវពលកម្មអន្តរជាតិ Vol. XXV,១៩៣២ ទំព័រ៣១៣ - ៣១៤។

តម្រូវយ៉ាងសមស្រប ថាត្រូវតែឲ្យមានសុចនាករសត្យានុម័ត និងដែលអាចផ្ទៀងផ្ទាត់បានថា ជនជាប់ឃុំដែលធ្វើការឲ្យអង្គភាពឯកជន ត្រូវធ្វើការដោយស្ម័គ្រចិត្តមែន។ ជាពិសេសគណៈកម្មាធិការនេះ បានថ្លែងថា មាត្រា ២(២) (គ) នៃអនុសញ្ញាលេខ ២៩ អនុញ្ញាតឲ្យជនជាប់ឃុំធ្វើការឲ្យក្រុមហ៊ុនឯកជនក៏បាន "តែនៅទីណាដែលជនជាប់ឃុំបំពេញការងារក្នុងលក្ខខណ្ឌទាំងឡាយ ដែលប្រហាក់ប្រហែលទៅនឹងទំនាក់ទំនងការងារសេរី"។[២៩] លើសពីនេះទៅទៀត ឈរលើតុល្យភាព "ពលកម្មជនជាប់ឃុំត្រូវធ្វើក្រោមកាលៈទេសៈ ដែលមិនគួរវិសមមាត្រពេក ដែលទាបជាងទីផ្សារសេរី ដែលអាចមានចរិតជាការកេងប្រវ័ញ្ច"។[៣០]

យោងតាមអង្គការពលកម្មអន្តរជាតិ សុចនាករនៃទំនាក់ទំនងការងារសេរីមានដាក់បញ្ចូលនូវព័ត៌មានដូចខាងក្រោម:

- ការយល់ព្រមជាផ្លូវការពីជនជាប់ឃុំជាលាយលក្ខណ៍អក្សរ ដើម្បីបំពេញការងារ ដោយមានទម្រង់បញ្ជាក់ពីប្រាក់ឈ្នួល និងលក្ខខណ្ឌការងារ។
- លក្ខខណ្ឌការងារ ដែលស្រដៀងទៅនឹងការងារក្រៅពន្ធនាគារ ពោលគឺ:
  - ✓ ប្រាក់ឈ្នួលប្រហាក់ប្រហែលនឹងប្រាក់ឈ្នួលកម្មករសេរី ដែលមានមុខជំនាញ និងបទពិសោធន៍ប្រហាក់ប្រហែលគ្នាក្នុងឧស្សាហាកម្ម ឬ មុខរបរដោយគិតគូរពីកត្តាទាំងឡាយ ដូចជាកម្រិតផលិតកម្ម តម្លៃដែលសហគ្រាសរ៉ាប់រងសម្រាប់ផ្នែកសន្តិសុខពន្ធនាគារ និងការត្រួតពិនិត្យមើលកម្មករ។
  - ✓ ប្រាក់ឈ្នួលបើកជូនកម្មករដោយផ្ទាល់។ កម្មករគួរទទួលបានស្លាកព័ត៌មានប្រាក់ឈ្នួលច្បាស់លាស់ និងពិស្តារ ដោយបញ្ជាក់ចំនួនម៉ោងបំពេញការងារ ចំនួនប្រាក់ឈ្នួលសន្សំបាន និងការកាត់ប្រាក់ឈ្នួលមួយផ្នែកណាមួយ ដែលអនុញ្ញាតដោយច្បាប់សម្រាប់ម្ហូបអាហារ និងការស្នាក់នៅ។
  - ✓ ម៉ោងបំពេញការងារប្រចាំថ្ងៃឲ្យស្របតាមច្បាប់។
  - ✓ វិធានការខាងសុវត្ថិភាព និងសុខភាពដែលគោរពច្បាប់។

---

[២៩] អង្គការពលកម្មអន្តរជាតិ របាយការណ៍ឆ្នាំ២០០៧ ស្តីពីការលុបបំបាត់ការងារដោយបង្ខំ: ជំពូក II។ អនុសញ្ញាស្តីពីការងារដោយបង្ខំ ឆ្នាំ១៩៣០ (លេខ ២៩) កថាខណ្ឌ១១៦។

[៣០] អង្គការពលកម្មអន្តរជាតិ របាយការណ៍ទូទៅរបស់គណៈកម្មាធិការអ្នកជំនាញ ស្តីពីការអនុវត្តន៍អនុសញ្ញា និងអនុសាសន៍ទាំងឡាយ ឆ្នាំ២០០១ កថាខណ្ឌ ១៤៣។

- កម្មករត្រូវបានដាក់បញ្ចូលទៅក្នុងផែនការណ៍សន្តិសុខសង្គម (បើអាចអនុវត្តទៅបាន) សម្រាប់ធានារ៉ាប់រងសុខភាព និងឧបទ្វវហេតុ។
- កម្មករទទួលផលប្រយោជន៍ ដូចជារៀនយកមុខជំនាញថ្មីៗ និងមានឱកាសបំពេញការងារដោយសហការក្នុងបរិយាកាសរៀបរយ ដែលអាចឲ្យពួកគេអភិវឌ្ឍមុខជំនាញតាមក្រុមនីមួយៗ។
- កម្មករមានលទ្ធភាពបន្តការងារប្រភេទដូចគ្នាបន្ទាប់ពីមានការដោះលែង។
- មានលទ្ធភាពដកការយល់ព្រមនៅគ្រប់ពេលវេលា ដោយអនុលោមទៅតាមលក្ខខណ្ឌតម្រូវ[៣១]ជូនដំណឹងសមហេតុផល។

លក្ខខណ្ឌតម្រូវនានាខាងលើអនុវត្តសម្រាប់អង្គភាពឯកជនទាំងអស់ ដែលប្រើជនជាប់ឃុំរាប់ទាំងអង្គភាពទាំងឡាយ ដែលគ្រាន់តែលក់ផលិតផលរបស់ពួកគេនៅក្នុងស្រុក។ អនុសញ្ញា ILO លេខ ២៩ មិនមានចែងពីការនាំទំនិញចេញទេ ហើយក៏មិនមានចែងពីភាពខុសគ្នារវាងក្រុមហ៊ុនលក់ផលិតផលក្នុងស្រុក និងក្រុមហ៊ុនដែលនាំចេញផលិតផលទៅលក់នៅក្រៅប្រទេសដែរ។ នេះជាចំណុចខ្វះខាតរបស់ប្រកាសនេះ។

## ស្ថានភាពក្នុងពន្ធនាគារនៅកម្ពុជា

ចាប់តាំងពីឆ្នាំ២០០៨ អង្គការលីកាដូ បានធ្វើសម្ភាសន៍ជាមួយជនជាប់ឃុំ ដែលត្រូវបានគេប្រើតាមកម្មវិធីការងារផ្សេងៗ ហើយគេបានរកឃើញថាមានសុចនាកម្មមួយចំនួនត្រូវបានបង្ហាញដូចខាងលើ។ ម៉្យាងវិញទៀតលក្ខខណ្ឌការងារនៅតាមពន្ធនាគារកម្ពុជាមិនមានភាពប្រហាក់ប្រហែលទៅនឹង "ទំនាក់ទំនងការងារសេរីឡើយ"។ លក្ខខណ្ឌទាំងនេះនៅដាច់ឆ្ងាយពីទំនាក់ទំនងការងារសេរី។

ជនជាប់ឃុំមិនបានចុះហត្ថលេខាលើទម្រង់យល់ព្រមជាផ្លូវការ ហើយទទួលបានប្រាក់ឈ្នួលមិនសមមាត្រទៅនឹងកម្មករនៅក្រៅពន្ធនាគារឡើយ។ ជនជាប់ឃុំខ្លះ ដែលអង្គការលីកាដូ ធ្វើសម្ភាសន៍ជាមួយបានអះអាងថា ពួកគេមិនបានទទួលប្រាក់ឈ្នួលទាល់តែសោះ ចំពោះអ្នកខ្លះទៀតបានទទួលប្រាក់ឈ្នួលចាប់ពី ១,០០០ រៀល (US$0.25) ទៅ

[៣១] អង្គការពលកម្មអន្តរជាតិ របាយការណ៍ឆ្នាំ២០០៧ ស្តីពីការលុបបំបាត់ពលកម្មដោយបង្ខំ: ជំពូក II។ អនុសញ្ញាស្តីពីពលកម្មដោយបង្ខំ ឆ្នាំ១៩៣០ (លេខ ២៩) កថាខណ្ឌ ១១៣ - ២០។ សំណួរ និងចម្លើយស្តីពីពាណិជ្ជកម្ម និងពលកម្មដោយបង្ខំ "អង្គការពលកម្មអន្តរជាតិ ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១០ មាននៅក្នុងគេហទំព័រ: http://www.ilo.org/empent/areas/business-helpdesk/faqs/ WCMS _DOC _ENT _HLP _FL _FAQ_EN/lang--en/index.htm។

៥,០០០ រៀល (US $1.25) ក្នុងមួយខែ។ ខ្លះរាយការណ៍ថា បានទទួលប្រាក់ឈ្នួលរហូតដល់ទៅ ២០,០០០ រៀល (US $5) ក្នុងមួយខែ។ អត្រាប្រាក់ឈ្នួលទាំងនេះ មានចំនួនសរុបប្រហែល ១% ទៅ ៨% នៃចំនួនប្រាក់ឈ្នួលតាមបទដ្ឋានអប្បបរមា ដែលស្មើនឹង ៦១ ដុល្លារអាមេរិកក្នុងមួយខែសម្រាប់កម្មករកាត់ដេរនៅកម្ពុជា។

តាមការដឹងពីអង្គការលីកាដូ ជនជាប់ឃុំមិនត្រូវបានអនុញ្ញាតឲ្យបង្កើតសហជីព ឬរៀបចំចាត់ចែង និងធ្វើការចរចារកិច្ចសន្យា ឬ លក្ខខណ្ឌការងារ ឬ ផ្លាស់ប្តូរការងារដោយសេរីឡើយ។ ដូចគ្នានេះដែរពុំមានការការពារត្រឹមត្រូវចំពោះសិទ្ធិកម្មករ ដូចជាការសំរាកមាតុភាព ការសំរាកព្យាបាលជម្ងឺ ប្រាក់សំណងសម្រាប់គ្រោះថ្នាក់ដល់របួសស្នាមនៅកន្លែងធ្វើការ ម៉ោងបំពេញការងារថ្ងៃឈប់សំរាក ប្រាក់ឈ្នួលធ្វើការលើសម៉ោង និងអាយុបំពេញការងារអប្បបរមា។

ជនជាប់ឃុំខ្លះរាយការណ៍ថា លក្ខខណ្ឌការងារមានលក្ខណៈគាបសង្កត់រាប់ទាំងការខ្វះខាតទឹក និងពេលសំរាកនៅក្នុងម៉ោងកំពុងបំពេញការងារ និងបញ្ហាផ្សេងៗទៀត។

នៅក្នុងករណីដ៏ធ្ងន់ធ្ងរបំផុតនោះ គឺជនជាប់ឃុំជាស្ត្រីមួយរូបរាយការណ៍ថា គាត់បានទទួលរងនូវអំពើទារុណកម្ម ទាក់ទងនឹងការងាររបស់គាត់ក្នុងរោងជាងកាត់ដេរសំលៀកបំពាក់នៅមណ្ឌលអប់រំកែប្រែទី២ នៅចុងឆ្នាំ២០០៩។ ជនជាប់ឃុំនោះអះអាងថា គាត់ធ្លាក់ខ្លួនឈឺនៅពេលកំពុងធ្វើការ រួចដើរចេញពីកន្លែងធ្វើការដើម្បីឈប់សំរាក។ ឆ្មាំពន្ធនាគារបញ្ជាគាត់ឲ្យវិលត្រឡប់មកធ្វើការវិញ ប៉ុន្តែគាត់មិនព្រមមក។ បន្ទាប់មកឆ្មាំពន្ធនាគារពីររូបបានវាយដំលើរាងកាយរបស់គាត់ ដោយប្រើស្បែកជើង និងខ្សែក្រវាត់។ ជនជាប់ឃុំនោះក៏បានបាត់បង់ការងារ ក្រោយពីទទួលរងការវាយដំ ហើយ ២០ ថ្ងៃក្រោយមកគេចាប់បង្ខំគាត់ឲ្យចំណាយពេលលំហែ ដោយលុតជង្គង់ក្នុងបរិវេណពន្ធនាគារនៅក្រោមកំដៅថ្ងៃ។ ក្រោយមកស្ត្រីនោះ បានបាត់បង់ពេលលំហែទាំងអស់ចំនួន ២០ ថ្ងៃបន្ថែមទៀត។

ថ្វីត្បិតតែការវាយដំមិនមែនជាបទដ្ឋានក៏ដោយ ក៏លក្ខខណ្ឌឃុំខ្លួនដ៏លើសលុបនៅក្នុងពន្ធនាគារកម្ពុជាធ្វើឲ្យទស្សនទាននៃ "ទំនាក់ទំនងការងារសេរី" ក្លាយជាជំនឿខុសឆ្គងមួយ។ ការបង្ខិតបង្ខំ គឺកើតមានជាប់ជាហូរហែ។

ជនជាប់ឃុំ ត្រូវបានគេដកហូតជាប្រចាំនូវសេចក្តីត្រូវការជាមូលដ្ឋានរាប់ទាំងម្ហូបអាហារគ្រប់គ្រាន់ ទឹក ពេលលំហែ ការថែទាំសុខភាព និងសន្តិសុខផ្ទាល់ខ្លួន។ តួយ៉ាងជន

ជាប់ឃុំអាចខ្វះមហូបអាហារជាដំរាប មានជម្ងឺដោយសារទឹកមិនស្អាត ហើយត្រូវការចំណាយខ្ពស់ទៅលើថ្នាំព្យាបាល ស្ថិតក្រោមការគំរាមកំហែងវាយដំ ឬ ដាក់ខ្នោះច្រវាក់ដោយសារខុសវិន័យ និងត្រូវការពេលវេលាចេញក្រៅបន្ទប់ឃុំខ្លួន ដែលមានសមត្ថភាពផ្ទុកជនជាប់ឃុំបាន ២០០%។ "បុព្វសិទ្ធិ" ភាគច្រើនត្រូវបានដោះដូរជាទំនិញ រាប់ទាំងពេលវេលាចេញក្រៅបន្ទប់ឃុំខ្លួន។ មានការលំបាកសម្រាប់ជនជាប់ឃុំក្នុងកាលៈទេសៈបែបនេះ ដើម្បីចូលរួមក្នុង "ទំនាក់ទំនងការងារសេរី" ជាពិសេសជាទូទៅនៅពេលជនជាប់ឃុំមានជម្រើសការងារដែលមានកំណត់ ហើយគ្មានសិទ្ធិបញ្ចេញមតិទាក់ទងនឹងលក្ខខណ្ឌការងារ។

ជនជាប់ឃុំដែលអង្គការលីកាដូ បានសម្ភាសន៍មានបំណងចង់ធ្វើការងារ ចង់ចេញក្រៅបន្ទប់ឃុំខ្លួនរបស់ពួកគេ និងចង់សន្សំប្រាក់ ហើយនឹងងាយទទួលរងការកេងប្រវ័ញ្ចលើកំលាំងពលកម្មរបស់គាត់។ សរុបសេចក្តីមកប្រទេសកម្ពុជាត្រូវធ្វើដំណើរវែងឆ្ងាយថែមទៀត ដើម្បីបង្កើតបរិយាកាសពន្ធនាគារ ដែលក្នុងបរិយាកាសបែបនេះ ជនជាប់ឃុំអាចមានលទ្ធភាពចូលរួមក្នុងទំនាក់ទំនងការងារសេរី។

## ជនជាប់ឃុំជាចរន្តប្រាក់ចំណូល

វាទំនងផងដែរដែល ថាការចាប់អារម្មណ៍ពីអាជ្ញាធរក្នុងកម្មវិធីពលកម្មជនជាប់ឃុំក្នុងពន្ធនាគារ គឺមិនមែនចាក់ឫសក្នុងទស្សនៈមិនអត្មានិយមទេ។ ជនជាប់ឃុំ គឺជាចរន្តប្រាក់ចំណូល ជាសក្តានុពលសម្រាប់ប្រព័ន្ធគ្រប់គ្រងពន្ធនាគារ។ យោងតាមរបាយការណ៍ខែមករា ឆ្នាំ២០១១ របស់អគ្គនាយកដ្ឋានពន្ធនាគារ កម្មវិធីការងារពន្ធនាគារផលិតបានប្រាក់ចំណូលជាង ១.០៣ កោដិរៀល (ប្រហែល US $257,000) នៅឆ្នាំ២០១០។[៣២] តួលេខនេះរាប់បញ្ចូលនូវកម្មវិធីទាំងអស់ចាប់ពីមុខរបរកសិកម្ម និងសិប្បកម្មឈើរហូតដល់ការផលិតសំលៀកបំពាក់កាត់ដេរ។

[៣២] អគ្គនាយកដ្ឋានពន្ធនាគារ របាយការណ៍ស្តីពីការងារសំរេចបានក្នុងឆ្នាំ២០១០ និងការធ្វើផែនការណ៍សំរាប់ឆ្នាំ២០១១ ចេញផ្សាយនៅខែមករា ឆ្នាំ២០១១ ទំព័រ៥ - ៦ បកប្រែក្រៅផ្លូវការជាភាសាអង់គ្លេស។ របាយការណ៍នេះ សរសេរថាជនជាប់ឃុំ ១,៨៣៥ នាក់ ត្រូវបានប្រើប្រាស់ពេញមួយឆ្នាំនៅអំឡុងឆ្នាំ ២០១០ មានន័យថា ជាមធ្យមជនជាប់ឃុំម្នាក់ៗសន្សំបានប្រាក់ចំណូលចំនួន ៩,០០០ រៀល (US $2.25) ក្នុងមួយខែ។

ជនជាប់ឃុំទទួលបានប្រាក់ចំណូលត្រឹមតែ ២០% ប៉ុណ្ណោះ ឬ ប្រហែល ២០០ លានរៀល (US$50,000) ដែលមានចំនួនសរុបប្រហែល ៩,០០០ រៀល (US$2.25) ក្នុងមួយខែសម្រាប់ជនជាប់ឃុំម្នាក់ ដោយប្រើប្រាស់តួលេខរបស់អគ្គនាយកដ្ឋានពន្ធនាគារ។[៣៣] ប្រាក់ចំណូលនៅសល់បានទៅមន្ត្រីពន្ធនាគារ ជាអ្នកទទួល (ចំនួនប្រហែល ៨០%)[៣៤] ចំណាយលើការកែលំអហេដ្ឋារចនាសម្ព័ន្ធ គម្រោងជួសជុលពន្ធនាគារកែលំអលក្ខខណ្ឌការងារសម្រាប់មន្ត្រីពន្ធនាគារសាងសង់ពន្ធនាគារថ្មី និងចំណាយលើការកែលំអផ្សេងៗទៀត។


*អ្នកជាប់ឃុំដេរសំលៀកបំពាក់អ្នកទោសក្នុងពន្ធនាគារខេត្តព្រះសីហនុ*

ជាក់ស្តែងអគ្គនាយកដ្ឋានពន្ធនាគារ បានចាប់ផ្តើមពឹងពាក់ ទៅលើកម្មវិធីពលកម្មជនជាប់ឃុំដើម្បីយកមូលនិធិមកផ្គត់ផ្គង់ដំណើរការរបស់ខ្លួន។ ហេតុការណ៍នេះ មិនមែនជាបញ្ហាចាំបាច់ទេ ការរៀបចំចាត់ចែងបែបនេះ គឺជារឿងធម្មតាទូទាំងពិភពលោកទៅហើយ។ ប៉ុន្តែ ការពឹងពាក់ទៅលើថវិកាដែលបានមកពីពលកម្មជនជាប់ឃុំ គឺមានអត្ថប្រយោជន៍ដែលត្រូវចងចាំ នៅពេលពិនិត្យទៅលើផលប៉ះពាល់ ដែលដៃគូពលកម្មសាធារណៈ និងឯកជន។ អគ្គនាយកដ្ឋានពន្ធនាគារទទួលបានការលើកទឹកចិត្តជាប្រាក់រង្វាន់ដើម្បីធ្វើអាជីវកម្មលើពលកម្មជនជាប់ឃុំ ហើយលុយអាចជាកត្តាមួយដ៏មានសារៈសំខាន់បំផុតក្នុងការជំរុញឲ្យបង្កើតដៃគូពលកម្មពន្ធនាគារសាធារណៈ និងឯកជន។ ត្រូវគាំទ្រក្នុងការបង្កើតកិច្ចការពារ ដើម្បីការពារសិទ្ធិទាំងឡាយរបស់ជនជាប់ឃុំតាមអនុសញ្ញា ILO លេខ ២៩។

- **អនុសាសន៍:** ប្រសិនបើប្រទេសកម្ពុជាមានបំណងអនុញ្ញាតឲ្យសហគ្រាសឯកជនប្រើប្រាស់ពលកម្មជនជាប់ឃុំក្នុងពន្ធនាគារ ប្រព័ន្ធគ្រប់គ្រងមួយត្រូវតែដាក់ឲ្យ

---

[៣៣] យោងឯកសារដូចគ្នានឹងជើងទំព័រទី៣២។

[៣៤] របាយការណ៍មិនបានបង្ហាញ ថាតើប្រាក់ចំណូលសម្រាប់បុគ្គលិកពន្ធនាគារ គឺប្រើសម្រាប់បៀវត្សធម្មតា ប្រាក់ឧបត្ថម្ភ ឬប្រាក់រង្វាន់ផ្សេងៗ ឬយ៉ាងណានោះទេ។

> មានដំណើរការ ដើម្បីធានាថា ត្រូវបំពេញលក្ខខណ្ឌតម្រូវនានាក្រោមអនុសញ្ញា ILO លេខ ២៩។ យ៉ាងហោចណាស់ប្រព័ន្ធគ្រប់គ្រងបែបនេះ ត្រូវតែមានក្នុងច្បាប់ពន្ធនាគារ ឬ អនុក្រិត្យដែលត្រូវតាក់តែងឡើងដោយមានកិច្ចពិគ្រោះយោបល់ពីអ្នកជំនាញអន្តរជាតិក្នុងវិស័យពលកម្មជនជាប់ឃុំក្នុងពន្ធនាគារ រាប់ទាំងអង្គការពលកម្មអន្តរជាតិ អង្គការពលកម្មដ៏ទៃទៀត ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា ព្រមទាំងសង្គមស៊ីវិលផងដែរ។

ជនជាប់ឃុំមិនត្រូវអនុញ្ញាតឲ្យធ្វើការបំរើសហគ្រាសឯកជនឡើយ រហូតទាល់តែកិច្ចធានាការពារទាំងឡាយនេះ ត្រូវបានដាក់ឲ្យមានដំណើរការ។ លើសពីនេះទៅទៀត ប្រសិនបើប្រព័ន្ធគ្រប់គ្រង ដែលអនុញ្ញាតឲ្យជនជាប់ឃុំធ្វើការបំរើអង្គភាពឯកជនត្រូវបានអនុវត្តនោះ អគ្គនាយកដ្ឋានពន្ធនាគារត្រូវបង្កលក្ខណៈឲ្យមានការឃ្លាំមើលដោយឯករាជ្យពីអង្គការសង្គមស៊ីវិល ដើម្បីធានាថាសិទ្ធិមានការងារធ្វើរបស់ជនជាប់ឃុំត្រូវបានគោរព។

អង្គការលីកាដូ អំពាវនាវសុំឲ្យអង្គការពលកម្មអន្តរជាតិចាត់វិធានការជំរុញប្រទេសកម្ពុជាឲ្យអនុវត្តតាមអនុសញ្ញាលេខ ២៩ ហើយនឹងធ្វើការឃ្លាំមើលការអនុវត្តន៍នេះ។ ផ្អែកលើករណីយុត្តិសាស្ត្រមុនៗរបស់ ILO វិធានការនេះ គួរដាក់បញ្ចូលអនុសាសន៍ថារដ្ឋាភិបាលកម្ពុជាត្រូវធ្វើវិសោធនកម្មច្បាប់ពន្ធនាគារ។[៣៥]

□□□

---

[៣៥] ឧទាហរណ៍សូមមើលអង្គការពលកម្មអន្តរជាតិ សំណើដាក់ជូន Botswana ដោយផ្ទាល់ពីគណៈកម្មាធិការអ្នកជំនាញស្តីពីការអនុវត្តន៍អនុសញ្ញា និងអនុសាសន៍ទាំងឡាយ អនុម័តនៅឆ្នាំ២០១១ ចេញផ្សាយ 101st ILC session (២០១២) (មាននៅក្នុងគេហទំព័: http:// www.ilo.org/dyn/normlex /en/f?p=1000:13100:2984050232233651::NO:13100:P13100_COMMENT_ID:2698190)។ Botswana បានអនុម័តច្បាប់មួយអនុញ្ញាតឲ្យប្រើជនជាប់ឃុំនៅក្រៅពន្ធនាគារក្រោមបទបញ្ជាបន្ទាន់ និងសម្រាប់ផលកម្រៃរបស់ជនជាប់ឃុំក្រៅពីអាជ្ញាធរសាធារណៈ។ Botswana បង្ហាញថាច្បាប់នេះ មិនធ្លាប់បានអនុវត្តជាក់ស្តែងទេ ប៉ុន្តែបើអនុវត្តជនជាប់ឃុំដែលចាត់ឲ្យទៅធ្វើការបំរើក្រុមហ៊ុនឯកជននឹងត្រូវធ្វើតាមឆន្ទៈដោយសេរីរបស់ខ្លួន។ ទោះបីយ៉ាងណាក៏ដោយ គណៈកម្មាធិការបានថ្លែងថាខ្លួន "សង្ឃឹមថានឹងចាត់វិធានការចាំបាច់ដើម្បីធ្វើវិសោធនកម្ម..ច្បាប់ពន្ធនាគារនេះ...សំដៅធានាថាជនជាប់ឃុំធ្វើការងារ ឬបំពេញសេវាណាមួយឲ្យក្រុមហ៊ុនត្រូវធ្វើដូច្នោះតាមការស្ម័គ្រចិត្ត ដោយផ្តល់ការយល់ព្រមដោយសេរី និងជាផ្លូវការ ការយល់ព្រមបែបនេះត្រូវបញ្ជាក់តាមលក្ខខណ្ឌ ការងារដែលមានលក្ខណៈប្រហាក់ប្រហែលទៅនឹងទំនាក់ទំនងការងារសេរី។ គណៈកម្មាធិការស្នើសុំរដ្ឋាភិបាលផ្តល់ព័ត៌មានស្តីពីភាពជឿនលឿនក្នុងវិស័យនេះ តាមរយៈរបាយការណ៍លើកក្រោយរបស់ខ្លួន"។